ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ១៩
ចុះថ្ងៃទី២៥-០២-៩៨
សាលដីកាលេខ៖១១
ចុះថ្ងៃទី២១-០៤-៩៩

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម... ប្រធាន
២-លោក ... ចៅក្រម
៣-លោក... ចៅក្រម
៤-លោក ... ចៅក្រម
៥-លោក ... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
លោក ....ព្រះរាជាណាចក្រកម្ពុជា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល។

ពីបទ៖ ធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៤បទល្មើស ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

១-ជនជាប់ចោទឈ្មោះ **អស** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិតាប៉ាវ ឃុំរកា៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម របររកស៊ីលក់រថយន្ត ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះ១២អា សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ...ម្តាយឈ្មោះ**...**ក្នុងឃុំ។ មាន មេធាវីអ្នកស្រី យសម។

២-ជនជាប់ចោទឈ្មោះ **អស** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាប៉ាវ ឃុំរកា៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម,របររកស៊ីរត់ម៉ូតូឌុប ទីលំនៅមុនថ្ងៃគេចខ្លួន ផ្ទះលេខ១២បេ ក្រុម១៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០២នាក់។ គេចខ្លួន។

-ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី **មសរ** (ជាចុងបណ្តឹងសាទុក្ខ) អាយុ៣៣ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥អា ផ្លូវលេខ៣៤៤ ក្រុមទី១៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ។

មេធាវីគ្មាន

តាមបណ្ដឹងសាទុក្ខលេខ៤៥៩ ចុះថ្ងៃទី២៧ខែវិច្ឆិកាឆ្នាំ១៩៩៧ របស់ឈ្មោះ **អស** ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧៣ ថ្ងៃទី១៣ ខែ វិច្ឆិកាឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៦-១២-១៩៩៤ និងចុះថ្ងៃទី១៧-១២-១៩៩៤ របស់ដើមបណ្ដឹងរដ្ឋប្បវេណីអ្នកស្រី **មសរ** ប្ដឹងពីឈ្មោះ **អស** និង **អស** ដែលបានព្រួតគ្នាវាយប្ដីខ្លួន បណ្ដាលឱ្យស្លាប់កាលពីថ្ងៃទី១៦-១៨-៩៤ វេលាម៉ោង៨ និង ៣០ នាទី។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ **អស** បានឆ្លើយប្រហាក់ប្រហែលគ្នានៅចំពោះមុខមន្ត្រីនគរបាល អយ្យការ ចៅក្រម ស៊ើបអង្កេត និងនាពេលសវនាការនៃតុលាការក្រុងភ្នំពេញថា៖ខ្លួនពុំបានវាយឈ្មោះ **អ** បណ្ដាលឱ្យស្លាប់ទេ ខ្លួនគ្រាន់តែចូលទៅឃាត់ប្អូនខ្លួន **អស** កុំឱ្យវាយប៉ុណ្ណោះ ប៉ុន្តែខ្លួនពុំបានឃើញ **អស** វាយដោយផ្ទាល់ភ្នែកទេ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ធ្វើសេចក្ដីសន្និដ្ឋានចោទលើឈ្មោះ **អស** និង **អស** ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធប្រព្រឹត្ដិ នៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១២-៩៤ តាមបញ្ញត្តិមាត្រា៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-១៩៩២។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤១(គ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេច៖

១-ផ្ដន្ទាទោសឈ្មោះ **អស** ដាក់ពន្ធាគារ កំណត់១០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦-១២-៩៤តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-ឱ្យ **អស** សងទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០ តម្លឹងមាស។ ក្នុងករណីមិនសងត្រូវរឹបអូសទ្រព្យសម្បត្តិ និងដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្តីពីការដាក់គុកបង្ខំរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ។

៣-ឱ្យឈ្មោះ **អស** រួចខ្លួនពីការចោទប្រកាន់ពីបទធ្វើមនុស្សឃាត ដោយចេតនាមានអាវុធ។

៤-ឱ្យដោះលែងជាបន្ទាន់ឈ្មោះ **អស** ភេទប្រុស អាយុ២៨ឆ្នាំ។

៥-វត្ថុតាងមានដំបងឈើ១ ត្រូវរឹបអូសនិងបំផ្លាញចោល។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខ **អស** កំបាំងមុខ **អស** សម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៤(គ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ របស់អ្នកស្រី **មសរ** ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ៤១ធ (គ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៤ របស់តុលាការក្រុងភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន ពេលសវនាការរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ **អស** ពិរុទ្ធភាពគ្រប់គ្រាន់តែឈ្មោះ **អស** មានពិរុទ្ធភាពគ្រប់គ្រាន់ និងចម្លើយសាក្សី ពុំមានភាពច្បាស់លាស់ទេ។ ដូច្នេះ សូមតុលាការតម្កល់សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម និងសូមពិចារណាទៅតាមច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍សម្រេច៖

១-ទទួលបណ្តឹង ចុះថ្ងៃទី៣០-៦-៩៥របស់ឈ្មោះ **មសរ** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលកមព្រហ្មទណ្ឌលេខ៤១(គ) ចុះថ្ងៃទី៣០-៦-៩៥ ទុកជាបានការលើកលែងតែចំណុចទី២,៣ និង ទី៤ ត្រូវបដិសេធចោល ហើយសម្រេចជាថ្មីដូចខាងក្រោម៖

ក-ផ្តន្ទាទោសឈ្មោះ **អស** ដាក់ពន្ធនាគារ កំណត់១០ឆ្នាំ គិតពីថ្ងៃសាលដីកាចូលជាស្ថាពរ តែទោសនេះ ត្រូវដក៦ ខែ១១ថ្ងៃចេញ ដោយឈ្មោះនេះបានទទួលរងរួចហើយពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦-១៦-៩៤តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ខ-ឱ្យឈ្មោះ **អស** និង **អស** សងជំងឺចិត្តក្នុងម្នាក់ចំនួន១០តម្លឹងមាសឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **មសរ**។ ក្នុងករណីជនល្មើសទាំងពីររឹងរូសមិនព្រមសងសំណងជំងឺចិត្តនេះត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ដើម្បីធានាសំណង បើសងមិនគ្រប់ ត្រូវដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **មសរ** កំបាំងមុខជនជាប់ចោទឈ្មោះ **អស** និង **អស** សម្រេចបើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញប្តឹងសាទុក្ខលេខ៤៥៩ ចុះថ្ងៃទី៧ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់អ្នកស្រី **មសរ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧ព ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះ**អស** (ម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៨ របស់អ្នកស្រី **មសរ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់អំណានសាវតាជាតិរបស់អ្នកស្រី **មសរ** (ជាចុងបណ្តឹងសាទុក្ខ)នៅពេលជំនុំជម្រះ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-បណ្តឹងសាទុក្ខរបស់ឈ្មោះ **អស** ស្ថិតក្នុងតំណត់ច្បាប់គប្បីលើកយកមករឿងនេះមកពិនិត្យពិចារណា។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣-១១-៩៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

-បានស្តាប់ចម្លើយអះអាង របស់ជនជាប់ចោទឈ្មោះ **អស** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា តុលាការថ្នាក់ក្រោមសម្រេចសេចក្តីយុត្តិធម៌កាលខ្ញុំឃាត់ជនរងគ្រោះ គឺដើម្បីឱ្យជនរងគ្រោះសងការខូចខាតឡានរបស់ខ្ញុំពោលគឺខ្ញុំពុំបានវាយជនរងគ្រោះឱ្យស្លាប់ទេ សូមជួយរកយុត្តិធម៌ឱ្យខ្ញុំផង។

-បានស្តាប់អំណានសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **មសរ** (ជាចុងបណ្តឹងសាទុក្ខ)នៅពេលជំនុំជម្រះ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារ អ្នកស្រី...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **អស** នៅពេលជំនុំជម្រះថា៖ តុលាការថ្នាក់ក្រោមស៊ើបអង្កេតពុំគ្រប់ជ្រុងជ្រោយ សូមក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោះ**អស**និងបន្តលើកលែងទោសចំពោះជនជាប់ចោទឈ្មោះ**អស**ទៀតផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការ របស់តំណាងមហាអយ្យការអមតុលាការកំពូល សូមតម្កល់ សេចក្តីសន្និដ្ឋានទុកនូវជដែល។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់ជនជាប់ចោទ សារណាតប របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៥៩ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ **អស** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា ការលើកឡើងរបស់មេធាវីការពារជនជាប់ចោទក្នុងសារណារបស់ខ្លួនថា៖ ការណ៍ដែលជនរងគ្រោះស្លាប់ ពុំមែនជាអំពើរបស់ឈ្មោះ **អស** ទេគឺបណ្តាលមកពីការវាយរបស់បងប្អូនជនរងគ្រោះតែម្តង ដែលក្នុងគោលបំណងវាយ **អស** តែដោយពេលនោះងងឹត ហើយជនរងគ្រោះនៅពីលើ **អស** ក៏នាំគ្នាវាយស្មានថា **អស** នៅពីលើនោះ គឺជាការពុំត្រឹមត្រូវឡើយពីព្រោះថា នៅកន្លែងកើតហេតុនោះពេលកំពុងវាយមានសាក្សី ឃើញច្បាស់បញ្ជាក់ថាឈ្មោះ **អស** កាន់ដំបង២កំណាត់ និងឈ្មោះ **អស** កាន់ដំបង៤ជ្រុងវាយទៅលើឈ្មោះ **នគស** បណ្តាលឱ្យស្លាប់។បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-យល់ឃើញថាការលើកឡើង របស់មេធាវីជនជាប់ចោទនាពេលសវនាការនេះថាៈបទល្មើសនេះមិនមែនជាបទមនុស្សឃាតដោយចេតនាទេ គឺជាបទល្មើសបង្ករបួសស្នាម ព្រោះថាជនរងគ្រោះមិនស្លាប់ នៅកន្លែងកើតហេតុ នោះជាការពុំត្រឹមត្រូវឡើយ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានកំណត់ថាចំបាច់ទាល់តែស្លាប់នៅកន្លែងកើតហេតុនោះទេ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណា ជូនតុលាការកំពូលរួចហើយ ប៉ុន្តែមិនបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី
ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៤៥៩ ចុះថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះ **អស** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ ។